# ឆ្ពោះទៅរកភរិយាភាព

ស៊ីន ចាន់ដឹប, ហ៊ីង ច័ន្ទថន

## ក្រមុំខ្មែរ

កាលណាឮពាក្យថា “ចូលម្លប់” មនុស្សច្រើនតែងតែគិតទៅដល់រឿង “ទុំទាវ” ហាក់ដូចជាយល់ថា ទំនៀមនេះបាត់បង់ជាយូរយារមកហើយ នៅសល់តែស្លាកស្នាមតាមអក្សរសាស្ត្រ។ បើយើងសួរទៅទៀតថា គេចូលម្លប់នោះដើម្បីអ្វី? គេច្រើនតែឆ្លើយថា គឺដើម្បីឲ្យកូនស្រីនោះរៀនវិជ្ជាមេផ្ទះ មានការដេណ្ដាំស្ល, ដេរប៉ាក់, រៀបចំផ្ទះសម្បែងជាដើម។ ចម្លើយនេះត្រូវតែមួយជ្រុងប៉ុណ្ណោះ ពោលគឺក្នុងគំនិតថា ទៅអនាគតមិនយូរមិនឆាប់នាងនោះនឹងទៅជាប្រពន្ធគេ ត្បិតមានចេញពាក្យថា “មេផ្ទះ”។ តាមពិតទៅ យើងនឹងឃើញថាក្មេងស្រីដែលចូលបន្ទុំខ្លួនក្នុងបន្ទប់បិទជិតនោះពុំអាចរៀនវិជ្ជាមេផ្ទះអ្វីបានទាំងអស់ សូម្បីតែបោសសំអាតផ្ទះខ្លួនឯងក្រៅពីបន្ទប់នោះក៏ធ្វើមិនកើតផង ដោយគេហាមមិនឲ្យចេញ។ កុំថាឡើយដល់ទៅគិតគូដណ្ដាំស្លឬធ្វើការងារអ្វីផ្សេងៗទៀត បើមានធ្វើអ្វីបន្តិចបន្តួចក្នុងបន្ទប់នោះ គឺគ្រាន់តែកំដរកុំឲ្យអផ្សុកខ្លាំងពេកប៉ុណ្ណោះ។ ឃើញថាចម្លើយពីមុនមកនោះពុំត្រូវនឹងការពិតឡើយ។ មួយវិញទៀត ការដែលស្មានថាទំនៀមចូលម្លប់នេះបាត់បង់ជាស្ថាពរហើយ គឺពុំមែនដូច្នោះទេ បើពោលក្នុងន័យទូទៅទើបថាបាន ត្បិតអីឃើញមាននៅតាមភូមិស្រុកក្នុងតំបន់នេះតំបន់នោះខ្លះៗដែរ ដែលគេនៅប្រតិបត្តិតាមប្រពៃណីនៅឡើយរហូតមកដល់សព្វថ្ងៃ។ តំបន់ដែលទំនៀមនេះនៅរស់រវើក គឺនៅស្រុកស្រែអំបិល ខេត្តកោះកុង (ជាពិសេសនៅឃុំស្រែអំបិល, ឃុំបឹងព្រាវ, ឃុំដងពែង), បន្ទាប់មកនៅស្រុកបាធាយ ខេត្តកំពង់ចាម (ជាពិសេសឃុំទំនប់, ឃុំតាំងក្រសាំង), បន្ទាប់មកទៀត នៅស្រុកសូទ្រនិគម ខេត្តសៀមរាប (ឃុំកៀនសង្កែ) ដែលនៅមានគេនិយមធ្វើខ្លះ គ្រាន់តែមិនខ្លាំងក្លាដូចតំបន់ពីរមុននេះ។ ផុតអំពីនេះទៅ និយាយជាស្រុកនេះស្រុកនោះឲ្យច្បាស់ពុំកើត តែក៏គង់ឃើញមានគ្រួសារខ្លះៗនៅធ្វើនៅឡើយ រាយប៉ាយនៅទីនេះបន្តិចទីនោះបន្តិច បើយើងពិនិត្យទៅតំបន់ដែលនៅប៉ែកខាងជើង ដូចជាក្នុងខេត្តឧត្តរមានជ័យនិងព្រះវិហារ។ នេះពោលពីស្ថានភាពសព្វថ្ងៃ។ បើពោលពីស្ថានភាពដែលមានមកទល់រវាងប្រមាណ៤០ឆ្នាំមុននេះ ស្រាវជ្រាវទៅឃើញថា ថ្វីត្បិតតែទំនៀម



រូបលេខ១ ៖ សែនដូនតាមុននឹងចូលម្លប់ (សាមីខ្លួនពាក់អាវស)



រូបលេខ២ ៖ ដំណាក់កាលមួយនៃការចេញពីម្លប់
(សាមីខ្លួននៅខាងស្តាំរូប)



រូបលេខ៣ ៖ ចងដៃក្នុងកិច្ចបញ្ចប់នៃការចេញពីម្លប់
(សាមីខ្លួនពាទាសំពត់ស)

ចូលម្លប់លែងប្រតិបត្តិជាទូទៅទៀតហើយក៏ដោយ ក៏គង់យើងអាចពោលថា មកទល់ពេលនោះនៅភូមិភាគខាងជើង គេនៅនិយមរៀបចំធ្វើខ្លះដែរ។ ការស្រាវជ្រាវអំពីទំនៀមចូលម្លប់នាបច្ចុប្បន្នមានរួចមកហើយកន្លងមកថ្មីៗនេះ។ ការរៀបរាប់លម្អិតមាននៅក្នុងសារណាបញ្ចប់ការសិក្សាពីរ[១]។ រីឯការពិចារណាលើន័យនៃកិច្ចផ្សេងៗក្នុងពិធីក៏មានធ្វើបន្ទាប់ពីនោះមកទៀត[២]។ ដូច្នេះ យើងខ្ញុំមិនយកមកពិពណ៌នាទៀតឡើយ។ ដែលនឹងយកមកនិយាយខ្លះៗខាងមុខ គឺគ្រាន់តែជាការរំលឹកគំនិតសំខាន់ៗដែលមានក្នុងនោះតែប៉ុណ្ណោះ។

គំនិតធំបង្អស់ គឺការចូលម្លប់ជាការឧបកិច្ចថា ក្មេងស្រីដែលចូលវ័យពេញក្រមុំហើយនោះមានប្តី ហាក់ដូចជាគេគិតថា ទាល់តែមានប្តីក្នុងន័យឧបកិច្ចយ៉ាងដូច្នេះ សិនទើបមានប្តីពិតប្រាកដទៅបាន។ កិច្ចគ្រប់បែបយ៉ាងនៅពេលចូលម្លប់និងចេញពីម្លប់សុទ្ធសឹងបង្ហាញថាកូនស្រីជាសាមីពិធីនោះមានគូ ហើយមានចាស់ទុំដឹងឮ។ នៅរូបលេខ១, ២និង៣ សាមីពិធីជាមនុស្សតែម្នាក់ រីឯអ្នកក្មេងស្រីម្នាក់ទៀត ដែលជាគូនោះក៏ជាមនុស្សតែម្នាក់ដូចគ្នា។ នៅរូបលេខ១អាចារ្យនាំគ្រួសារព្រមទាំងកូនស្រីទាំងពីរសែនដូនតាឲ្យដឹងឮ មុននឹងឲ្យសាមីពិធីចូលទៅក្នុងម្លប់ ពោលគឺចូលទៅនៅក្នុងបន្ទប់មួយចេញមកក្រៅមួយភ្លែតៗបានតែពេលយប់សម្រាប់ការចាំបាច់ផ្សេងៗ។ រូបលេខ២ ស្រង់យកអំពីពេលចេញពីម្លប់វិញ ក្រោយពីរស់នៅក្នុងបន្ទប់តែឯងអស់មួយរយៈពេល។ រូបកន្លែងនេះនៅត្រង់កិច្ចធ្វើធ្មេញ ហើយយើងឃើញថា អ្នកទាំងពីរមក

[១] ស៊ុន ចាន់ដឹប២០០៣ និង ស៊ុន ចាន់ដឹប២០០៦។
[២] អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប ២០០៧។

អង្គុយសំពះផ្ទឹមជាមួយគ្នាដូចក្នុងមង្គលការដូច្នោះ។ រូបលេខ១៣ គឺនៅពេលធ្លងបុណ្យបញ្ចប់ពិធីចេញពីម្លប់។ យើងឃើញថា ចាស់ទុំ "ជជុះរលាស់" ពោលគឺប្រោះព្រំ ឲ្យពរអ្នកទាំងពីរហាក់ដូចជាសន្មតថាជាគូស្វាមីភរិយាដូច្នោះ។

តើការដែលមើលទៅដូចជាឧបកិច្ចថាក្មេងស្រីនោះមានប្ដីហើយមានន័យថាដូចម្ដេច? គឺមានន័យថា ដំណើរពីក្រមុំទៅកាន់ភាពជាភរិយានោះ សង្គមពីមុនមកយល់ថាត្រូវធ្វើវែងឆ្ងាយខ្លាំងណាស់ ពុំមែនត្រឹមតែមានការស្ទាបស្ទង់ (ដោយប្រើ "អ្នកផ្លូវ") បន្ទាប់មកការសួរសាកល្បង (ដោយប្រើ "អ្នកចែចូវ") បន្ទាប់មកទៀតការស្ដីដណ្ដឹងពេញមុខ (ដោយប្រើ "អ្នកមហា") មុននឹងមកដល់មង្គលការប៉ុណ្ណោះទេ គឺថាកូនស្រីនោះត្រូវទុំខ្លួនសិន ទើបអាចទៅប្រឈមនឹងការស្ដីដណ្ដឹង។ ភាពដែលអាចចាត់ទុកថា "ទុំ" នោះជាលទ្ធផលនៃការបន្ទុំខ្លួនកូនស្រីក្នុងម្លប់នោះឯង ដោយឆ្លងកាត់ពិធីយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយដែលជាការឧបកិច្ចថាមានប្ដី។ អាចនិយាយម្យ៉ាងទៀតថា ឧបកិច្ចហើយមួយតំណាក់កាលសិន ទើបធ្វើកិច្ចពិតប្រាកដដែលហៅថាមង្គលការ។ ដូច្នេះចូលម្លប់ជាតំណាក់កាលទី១ក្នុងដំណើរឆ្ពោះទៅរកភរិយាភាព។

## ជយនៅមើលជាតិពន្ធុជាបងប្អូន

គំនិតថាឆ្ពោះទៅរកភរិយាភាពត្រូវឆ្លងដំណាក់កាលពីរធំៗនោះសោត ពុំមែនមានចំពោះតែខ្មែរប៉ុណ្ណោះទេ គឺច្បាស់ជាជាតិសាសន៍ដទៃទៀតជាច្រើនមានដែរ គ្រាន់តែលំនាំនៃការប្រតិបត្តិខុសៗគ្នា។ នៅទីនេះយើងខ្ញុំនឹងលើកយកទំនៀមជាតិពន្ធុមួយពួកឈ្មោះថាគ្រឹង ដែលរស់ផ្ដុំគ្នាតាមភូមិមួយចំនួនក្នុងខេត្តរតនគិរី ជាពិសេសនៅស្រុកអូរជុំ។ តែមុននឹងនិយាយដល់នោះ យើងខ្ញុំសូមពោលពីរបីម៉ាត់សិនអំពីស្ថានភាពជាតិសាសន៍ទូទៅនៃតំបន់ដែលនឹងលើកមកនេះ។ ជាតិពន្ធុសុទ្ធសាធផ្សេងៗដែលរស់នៅតំបន់នេះ ហើយដែលភាសានៅក្នុងអម្បូរមន_ខ្មែរ មានគ្រឹង, ទំពួន, ការ៉ែត, ព្រៅ, លុន ជាដើម។ ឯក្រុមដែលនៅក្នុងអម្បូរភាសាអូស្ត្រូណេស៊ីមានជាអាទិ៍គឺជ្រាយនិងកាចក់។ ជាតិសាសន៍ទាំងអស់នេះ ជាទូទៅមានរបៀបរស់នៅទំនៀមទម្លាប់ប្រហាក់ប្រហែលគ្នា ថ្វីត្បិតតែក្រុមនីមួយៗមានបុគ្គលិកលក្ខណៈខ្លួនផ្ទាល់។ ពីមុនមក ភូមិនានាច្រើនតែមានរាងមូល (រូបលេខ១៤) បើពុំនោះទេក៏មានទម្រង់ជាពងក្រពើដែរ[៣]។ ជាទូទៅផ្ទះសង់នៅតាមខ្សែមូលឬពងក្រពើនោះឯង ហើយបែរមុខមកក្នុងរកគ្នាទាំងអស់។ នៅកណ្ដាលភូមិមានអាគារមួយធំវែងរបស់អ្នកភូមិទាំងមូលហៅថា "រោង"។ និយាយមកដល់នេះ សូមបញ្ជាក់សិនថា ជាប្រពៃណីរៀងមកភូមិនិមួយៗ តែងមានចាស់ស្រុកចំនួនប្រមាណពីរឬបីនាក់ ដែលនៅក្នុងភាសាមន_ខ្មែរហៅថា "ក្រាក់"[៤]។ ក្រាក់ទាំងនេះ អ្នកភូមិទាំង

---

[៣] សព្វថ្ងៃនេះ រូបរាងភូមិមានការប្រែក្លាយច្រើនដោយប្រការផ្សេងៗ ដែលយើងខ្ញុំពុំយកមកវែកញែកនៅទីនេះឡើយ។

[៤] ក្នុងភាសាខ្មែរ និយមន័យនៃពាក្យនេះ ច្រើនសំដៅទៅលើសាច់ខ្លឹមឈើ។ យូរៗម្ដងគេនិយាយសំដៅអំពីមនុស្សដែលមានឥទ្ធិពល។ បើខ្មែរនិយាយអំពីចាស់ទុំដែលគេស្ដាប់យោបល់ក្នុងវង្សជាតិពន្ធុដូចយើងពោលនេះ ខ្មែរតែងថា "មេកន្ទ្រាញ"។



រូបលេខ១៤ ៖ ភូមិជនជាតិព្រៅមួយនាទសវត្ស១៩៦០
(ប្រភព ៖ *Matras-Troubetzkoy 1983*)

មូលតែងពិគ្រោះ ហើយស្ដាប់យោបល់ក្នុងការសម្រេចចិត្តអ្វីមួយ រាប់បញ្ចូលទាំងការសែនភូមិ, រៀបការប្ដីប្រពន្ធ, កាត់ក្ដី, ផាកពិន័យលើអ្នកស្រុកដែលធ្វើខុសឆ្គងអ្វីទាំងពួង។ កិច្ចប្រជុំទាំងអស់នេះតែងមានក្រាក់ជាប្រធាន ហើយប្រព្រឹត្តទៅនៅរោងនេះឯង។ នេះជាមុខងារសំខាន់បំផុតរបស់រោង។

ចំណែកឯមុខងារទីពីររបស់រោង គឺយប់ឡើង ក្មេងប្រុសពេញកម្លោះតែងមកជុំគ្នាដេកនៅទីនោះ[៥]។ សូមបញ្ជាក់ថា ករណីទីពីរនេះ ពុំមែនត្រូវតែធ្វើខានមិនបានទេ ព្រោះក្មេងកម្លោះខ្លះនិយមធ្វើកូនផ្ទះតូចៗ ទាបឬខ្ពស់សម្រាប់ដេកពេលយប់ជាក្រុមៗជាមួយគ្នា។ ក្នុងមួយផ្ទះអាចមានបីឬបួននាក់ជាដើម។ ទោះជាមិនដេកនៅរោងក៏ទំនាក់ទំនងជាមួយរោងនៅតែមានដដែល ត្បិតកូនផ្ទះនោះតែងតែបែរទៅរោងជានិច្ច។ រូបលេខ១៥_៦ បង្ហាញពីផ្ទះកម្លោះជនជាតិគ្រឹង។



រូបលេខ១៥ ៖ ភូមិគ្រឹង, ផ្ទះកម្លោះបែរមុខទៅរោង



រូបលេខ១៦ ៖ ភូមិគ្រឹង, ផ្ទះកម្លោះមួយទៀតបែរមុខទៅរោងដូចគ្នា

[៥] ទំនៀមនេះ ជាតិសាសន៍តូចៗច្រើនណាស់ដែលមានដូចគ្នា ទោះជានៅទ្វីបដទៃទៀតក្រៅពីអាស៊ីក៏ដោយ។ អ្នកស្រាវជ្រាវតែងហៅថា *bachelor's house*។

ចំពោះក្មេងស្រីដែលទើបពេញក្រមុំវិញ ការបន្ទុំខ្លួនក៏មានដែរ ប៉ុន្តែសព្វថ្ងៃនេះ ក្រៅអំពីជនជាតិគ្រឹង ទំនៀមទាក់ទងនឹងស្រីក្រមុំមានការប្ដូរផ្លាស់ច្រើន យ៉ាងហោចណាស់ក៏ដូរសម្បកក្រៅដែរ មានន័យថាអ្នកក្រៅមានខ្មែរជាដើម ប្រសិនបើទៅទស្សនាភូមិជាទេសចរសាមញ្ញនោះ ក៏ពុំងាយនឹងចាប់អារម្មណ៍លើការបន្ទុំខ្លួននេះទេ។ នៅរូបលេខ២៧ ដែលបង្ហាញពីផ្នែកខាងក្នុងនៃផ្ទះមួយនៃជនជាតិជ្រាយ យើងឃើញមានបន្ទប់មួយតូចចង្អៀតដែលគេធ្វើសម្រាប់ឲ្យស្រីក្រមុំម្នាក់ចូលដេកនៅពេលយប់។ ក្នុងន័យថា "បន្ទុំខ្លួន" នៅទីនេះគ្មានអ្វីដែលស្ដែងនឹងភ្នែកខ្លាំង ដូចការចូលម្លប់នៃក្មេងស្រីខ្មែរទេ ព្រោះនៅឯនេះក្មេងស្រីប្រកបការងារនៅក្រៅផ្ទះនិងនៅចម្ការដូចគេដូចឯង គ្មានត្រណមឲ្យឃុំខ្លួនអ្វីទាំងអស់ គ្រាន់តែយប់ពេលដេកក៏ចូលដេកក្នុងបន្ទប់ដ៏តូចចង្អៀតនោះទៅ។ រូបលេខ២៨ក៏ដូចគ្នាដែរ តែនេះជាផ្ទះនៅភូមិជនជាតិទំពួន[៦]។ រឿងអ្វីតអំពីនោះទៅទៀត យើងនឹងនិយាយក្នុងជំពូកដែលទាក់ទងនឹងជនជាតិគ្រឹងបន្ទាប់ទៅនេះ។



រូបលេខ២៧ ៖ បន្ទប់ក្មេងស្រីក្រមុំក្នុងផ្ទះមួយនៃជនជាតិជ្រាយ



រូបលេខ២៨ ៖ បន្ទប់ក្មេងស្រីក្រមុំក្នុងផ្ទះមួយនៃជនជាតិទំពួន

## ក្រមុំគ្រឹង[៧]

ដូចទើបនឹងនិយាយមកហើយ ការបន្ទុំខ្លួននោះគ្មានអ្វីជាតឹងរឹងឡើយ គឺគ្រាន់តែពេលដេកយប់ក៏ចូលដេកក្នុងនោះទៅ។ ដែលគួរឲ្យកត់សម្គាល់វិញ គឺក្មេងស្រីពេញក្រមុំនោះអាចទទួលកម្លោះនៅក្នុងបន្ទប់ខ្លួនបាន បើខ្លួនពេញចិត្ត ហើយបើមើលទៅឃើញថាដូចជាមិនទាស់ខុសអ្វីជាមួយឪពុកម្ដាយដែលនៅក្នុងផ្ទះជាមួយគ្នានោះ។ តាមពិតទៅ នេះជាចេតនានៃឪពុកម្ដាយនោះឯងហើយ ព្រោះការរើសគូស្រករ គឺសាមីខ្លួនផ្ទាល់ជាអ្នករើស ថ្វីត្បិតតែជួនកាលឪពុកម្ដាយមាន

[៦] អ្នកផ្ទះនោះទៅនៅចាំចម្ការអស់ហើយ ទើបបានជាមើលទៅឃើញល្ហល្ហេវហាក់ដូចជាផ្ទះបោះបង់ចោល។

[៧] ការសិក្សាអំពីជនជាតិគ្រឹងមានមួយចំនួនដែរ ក្នុងនោះមានពីរដែលទាក់ទងនឹងប្រធានបទនេះ ៖ ជ័យ រតនា និង ឡុង ពៅ ២០០១_២០០២ និង ហ៊ីង ច័ន្ទថន ២០០៧។ ចំពោះការសិក្សាជ្រៅជ្រះអំពីកសិកម្ម និងទំនៀមខ្លះនោះ សូមអាន Matras-Troubetzkoy 1983.

សម្តែងការពុំពេញចិត្តលើកម្លោះនេះឬកម្លោះនោះ ដោយលើកយកប្រការណាមួយមកថ្លែង។ ដូច្នេះបន្ទប់តូចនោះសម្រាប់ឲ្យក្មេងស្រីនិងប្រុសទាក់ទងគ្នា ស្គាល់ចិត្តគ្នា មុននឹងសម្រេចថាយកគ្នាជាប្តីប្រពន្ធ។ យ៉ាងណាក៏ដោយ កម្លោះនោះមិនអាចឡើងមកសំណេះសំណាលឬធ្វើអ្វីលើសនោះទៅទៀតទេ ប្រសិនបើគ្មានការយល់ព្រមពីកូនស្រី។ ជួនកាលទៀត ដោយសារនៅអៀនអន់នៅឡើយ នៅលើកទីមួយឬលើកទីពីរកម្លោះដែលមានចិត្តស្នេហាលើស្រីនោះតែងនាំគ្នាម្នាក់ពីរទៅជាមួយ។ ក្រោយពីនោះមក ប្រសិនបើមើលទៅឃើញថាអាចត្រូវរ៉ូវគ្នា ទើបមកម្នាក់ឯង។ តែទោះជាយ៉ាងណាក៏មិននៅបន្ទប់នោះហួសពីពីរម៉ោងជាដើមឡើយ ឧទាហរណ៍បើទៅដល់ម៉ោងប្រាំបី (គឺពេលដែលជាទូទៅគេចាប់ផ្តើមដេកហើយ) ក៏ត្រឡប់មកកន្លែងខ្លួនវិញវវាងម៉ោងដប់យប់នោះដែរ។ លុះឃើញតែកម្លោះដដែលនោះទៅញឹកញាប់ហើយ ឪពុកម្តាយក៏យល់យ៉ាងងាយថា អ្នកទាំងពីរនោះស្រឡាញ់គ្នា។ ឯការបានខ្លួនឬមិនបានខ្លួនគ្នាពុំសំខាន់ណាស់ណាទេក្នុងដំណាក់កាលនេះ។


រូបលេខ៩ ៖ ភូមិគ្រឹង ៖ ផ្ទះក្មេងស្រីក្រមុំបែរមុខទៅផ្ទះធំ


រូបលេខ១០ ៖ ផ្ទះដដែលនោះបែរខ្នងឲ្យរោងភូមិ

ឥឡូវចូរយើងនិយាយមកដល់ផ្ទះកូនក្រមុំ។ ត្រង់ចំណុចនេះ ជនជាតិគ្រឹងនៅប្រកាន់ប្រពៃណីខ្ជាប់ខ្ជួនជាងជនជាតិខ្លះទៀតដូចជាជនជាតិព្រៅជាដើម ដែលពីមុនមកធ្លាប់មានផ្ទះកូនក្រមុំដែរ ហើយដែលទើបនឹងបោះបង់ទំនៀមនេះចោល។ មានគ្រួសារគ្រឹងច្រើន ដែលនៅធ្វើផ្ទះឲ្យកូនក្រមុំនៅដាច់ដោយឡែកក្បែរផ្ទះធំ។ ផ្ទះនេះមានលក្ខណៈសម្គាល់ខ្លះៗ ដូចជាមានទំហំតូចទាប ជួនកាលប្រកចូលតូចខ្លាំងណាស់ ឬជួលកាលទៀតដាក់តែឈើឬថ្មមួយដុំជំនួសជណ្តើរជាដើម។ ត្រឹមតែប៉ុណ្ណោះក៏ពុំទាន់ច្បាស់ថាជាផ្ទះកូនក្រមុំដែរ ព្រោះអាចជាផ្ទះបណ្តោះអាសន្នសម្រាប់ស្រីឆ្លងទន្លេ ឬមួយសម្រាប់មនុស្សចាស់ទ្រុឌទ្រោមជាដើម។ ដែលឲ្យឃើញច្បាស់នោះ គឺផ្ទះកូនក្រមុំពុំដែលនៅក្រោយផ្ទះធំដូចផ្ទះឆ្លងទន្លេឡើយ តែនៅមកខាងមុខ ហើយបែរទៅចំផ្ទះធំ (រូបលេខ៩) បើពុំនោះទេក៏បែរបញ្ឆិតមកផ្ទះធំដែរ ហាក់ដូចជាមានន័យថា ឪពុកម្តាយនៅសម្លឹងមករក ឬមួយថា ទោះជា "ឯករាជ្យ" ច្រើនជាងនៅបន្ទប់ក្នុងផ្ទះ ក៏កូនស្រីនោះស្ថិតនៅក្រោមឱវាទនៃឪពុកម្តាយដែរ។ ផ្ទះតូចនោះគ្រាន់តែជាចំណុះនៃផ្ទះធំប៉ុណ្ណោះ។ ម្យ៉ាងទៀត ដោយសារបែរទៅផ្ទះធំដូច្នោះ ផ្ទះកូនក្រមុំក៏បែរខ្នងជាស្វ័យប្រវត្តិទៅឲ្យរោង (រូបលេខ១០) បីដូចជាបែរខ្នងទៅឲ្យកម្លោះដែរ ត្បិតយើង

ឃើញពីលើមកថាជួនកាលកម្លោះបបួលគ្នាច្រើនឬតិចទៅដេកនៅរោង។ ទោះជាដេកនៅកូនផ្ទះ ក៏ផ្ទះកម្លោះនេះបែរចំមករោងដូចបានឃើញមកហើយដែរ។ នេះជាភាពផ្ទុយគ្នាមួយ ផ្ទុយគ្នាមួយទៀតគឺទោះជានៅរោងឬនៅកូនផ្ទះតូចៗដាច់ចេញពីឪពុកម្តាយ កម្លោះតែងដេកជុំគ្នាជាក្រុមតូចក្តីធំក្តី[៨] រីឯបន្ទប់ក្នុងផ្ទះឬផ្ទះកូនក្រមុំវិញ គឺគេធ្វើឡើងសម្រាប់ក្រមុំម្នាក់ៗ ពុំមែនសម្រាប់ក្រុមឡើយ។ ចំណុចខុសគ្នាមួយទៀត គឺកាលណាលែងត្រូវការផ្ទះតូចនៅហើយ កម្លោះអាច “លក់” ផ្ទះនោះឲ្យកម្លោះដទៃទៅបន្ត ចំណែកឯកូនក្រមុំវិញ បើឈប់នៅកូនផ្ទះហើយ ផ្ទះនោះត្រូវរុះចេញឬមួយបើមានប្តីពេញមុខហើយ អាចលើកបំបែរផ្ទះនោះលែងឲ្យបែរទៅរកផ្ទះធំទៀត។

បើនៅបន្ទប់ក្នុងផ្ទះធំ កូនស្រីនោះអាចទទួលកម្លោះហើយ មានន័យថាមកនៅកូនផ្ទះដាច់ពីផ្ទះធំ ការទទួលនោះកាន់តែងាយស្រួលទៅទៀត ព្រោះពុំទើសមុខទើសមាត់ម៉ែឪនិងបងប្អូន។ ម្យ៉ាងទៀត ឪពុក, បងប្រុស ឬនរណាទៀតដែលសម្អិតសម្អាងសង់កូនផ្ទះឲ្យនោះ គឺធ្វើឡើងក្នុងគោលបំណងនេះឯង។ ជាធម្មតា មកដេកនៅកូនផ្ទះដាច់តែឯងដូច្នេះហើយ មិនយូរមិនឆាប់តែងតែមានកម្លោះមកលេង។ នៅឯនេះ ការស្នាក់នៅអាចហួសពីមួយម៉ោងពីរម៉ោងដូចកាលនិយាយពីនៅបន្ទប់។ បើពិនិត្យមើលរូបលេខ១០អម្បាញ់មិញឲ្យច្បាស់ យើងឃើញថាស្អែកឡើងរវាងម៉ោងប្រមាណ១០ព្រឹកហើយក៏ឃើញស្បែកជើងស្រីមួយគូប្រុសមួយគូពុំទាន់បែកខ្ញែកទៅទីណាពីរានលើជណ្តើរនោះផង។

ទិន្នន័យដែលយើងខ្ញុំប្រមូលបានដោយបទសម្ភាសន៍ក្តី ដោយការពិនិត្យផ្ទាល់ក្តី គឺមានច្រើនណាស់ ដូច្នេះករណីដែលបានស្រង់មកក៏មានផ្សេងៗគ្នាច្រើនដែរ។ តែនៅទីនេះយើងខ្ញុំសូមលើកយកតែករណីទាំងឡាយណាដែលកើតមានឡើងញឹកញាប់ជាធម្មតា ដើម្បីជាការសង្ខេបថា ដូចម្តេចដែលសង្គមគ្រឹងយល់ថាប្រក្រតី ហើយដូចម្តេចវិញដែលយល់ថាពុំប្រក្រតី។ ចំណុចមួយដែលយើងអាចយល់យ៉ាងងាយ គឺប្រហែលជាគ្មានទេ ការដែលនៅជាមួយគ្នាច្រើនយប់រាប់ពុំអស់រហូតដល់ឪពុកម្តាយទាំងសងខាងអនុញ្ញាតឲ្យរៀបការ ហើយដែលពុំបានខ្លួនប្រាណគ្នានោះ។ ដូច្នេះ ការដែលមានផ្ទៃពោះមុនរៀបការជារឿងដែលមានញឹកញាប់។ កំពុងមានផ្ទៃពោះ គេមិនទាន់ឲ្យរៀបការទេ ទាល់តែឆ្លងទន្លេផុតហើយទើបឲ្យការបាន។ ករណីនេះ ទោះជាពុំមែនភាគច្រើនក៏គង់មានច្រើនដែរ។ តែបើពោលថា អ្នកទាំងពីរនោះគេចាត់ទុកថាជាប្តីប្រពន្ធពេញមុខ សង្គមទទួលស្គាល់ពេញច្បាប់ក៏ពុំទៀងថាដូច្នោះ ព្រោះនៅភូមិខ្លះគេអនុញ្ញាតឲ្យរៀបការ

[៨] ក្នុងប្រពៃណីខ្មែរ ទោះបីជាសព្វថ្ងៃច្រើនមានឃើញតែនៅតាមជនបទក្តី ក៏ក្មេងកម្លោះតែងបួសនាគជាក្រុម ចាកចោលផ្ទះឪពុកម្តាយដែលខ្លួនធ្លាប់នៅ ដើម្បីទៅរៀនសូត្រនៅវត្តក្នុងភាពជាសង្ឃ។ ដោយចៀសវាងចាកប្រធានបទ យើងខ្ញុំពុំលើកការប្រៀបធៀបប្រុសកម្លោះខ្មែរទៅប្រុសកម្លោះជាតិពន្ធមានគ្រឹងជាដើមនេះឡើយ ថ្វីត្បិតតែជារឿងដែលមានសារសំខាន់ ព្រោះទីនេះនិយាយតែពីដំណើររបស់មនុស្សស្រីចាប់អំពីពេលពេញក្រមុំ ទៅដល់ភាពជាភរិយាពេញមុខ។

ជាធម្មតា[៩] តែនៅភូមិខ្លះទៀត[១០] ក្រាក់ឲ្យ “ផាក” ទាំងពីរនាក់ជាមុនសិន ទើបឲ្យរៀបការជាក្រោយ[១១]។

បើបានខ្លួនប្រាណគ្នាតែពុំទាន់មានកូន ហើយអ្នកទាំងពីរព្រមព្រៀងគ្នារៀបការ នោះកាន់តែប្រសើរណាស់ទៅទៀត។

ម្យ៉ាងទៀត ក្នុងរយៈពេលពីមួយឆ្នាំទៅមួយឆ្នាំកន្លះ[១២] អាចមានកម្លោះប្រុសលើសពីម្នាក់ដែលធ្លាប់ចូលទៅក្នុងកូនផ្ទះនោះពេលយប់ មានន័យថាជួនកាលអ្នកខ្លះចូលទៅសាសង់គ្នាម្តងឬច្រើនដងតែមិនត្រូវរ៉ូវគ្នា ឬមួយត្រូវគ្នាអស់មួយរយៈពេលដែរ តែក្រោយមកទៀតបែកគ្នាទៅវិញដោយប្រការណាមួយ ទើបក្រោយមកមានកម្លោះណាម្នាក់ផ្សេងទៀតទៅសាកសួរចិត្តហើយនៅជាមួយគ្នាតមក។ ទោះជាក្មេងក្រមុំនោះធ្លាប់ទទួលកម្លោះខុសៗគ្នា បន្តបន្ទាប់គ្នាក៏ដោយក៏អ្នកភូមិមិនជៀលត្អិះអ្វីដែរ ត្បិតការដែលសំខាន់គឺអ្នកដែលស្រឡាញ់គ្នា ទីបំផុតទៅរៀបការគ្នាជាប្តីប្រពន្ធ។

បើមានកូនហើយ ទីបំផុតទៅប្រុសមិនយកនាងនោះជាប្រពន្ធ គឺគេត្រូវផាកប្រុស ហើយផាកនោះសោតក៏ពុំមែនតិចតួចដែរ ត្បិតគេចាត់ទុកថាជាកំហុសធ្ងន់ មានន័យថាក្រាក់តែងតែដាក់សម្ពាធយ៉ាងណាឲ្យមនុស្សប្រុសនិងស្រីគោរពវិន័យរបស់សង្គមក្នុងការបង្កបង្កើតគ្រួសារជៅសន្តាន។ យើងធ្លាប់ប្រទះឃើញករណីមួយដែលប្រុសនិងស្រីនៅភូមិផ្សេងគ្នា។ លុះមកនៅជាមួយកូនស្រីបានយូរបន្តិចមក ប្រុសនោះត្រឡប់ទៅជាបោះបង់ស្រីចោលដោយគ្មានហេតុផលអ្វីត្រឹមត្រូវទាំងអស់។ ដោយសារប្រុសនោះមកពីភូមិផ្សេង អ្នកភូមិខាងស្រីយល់ថាជាការមិនគប្បី នាំឲ្យអាមាស់មុខខ្លាំងណាស់ ថ្វីត្បិតតែកូនស្រីនោះពុំមានផ្ទៃពោះក៏ដោយ។ ពេលនោះក្រាក់ស្រុកព្រមទាំងឪពុកម្តាយខាងស្រីនាំគ្នាទៅចរចាជាមួយក្រាក់ស្រុកនិងឪពុកម្តាយខាងប្រុស។ សម្រេចគ្នាទីបញ្ចប់ទៅគឺត្រូវសែនផ្តាច់ មានន័យថាពីរនាក់នេះពុំបានគ្នាជាប្តីប្រពន្ធឡើយ តែប្រុសនោះត្រូវមកសែនជម្រះមន្ទិលឲ្យគ្រួសារព្រមទាំងអ្នកភូមិខាងស្រីដោយត្រូវបង់ផាកជាប្រាក់២លានរៀល ដើម្បីខាងស្រីទិញរណ្តាប់សំណែនសព្វគ្រប់ធ្វើកិច្ចនោះ ហើយនឹងទុកប្រាក់ខ្លះជាជម្ងឺចិត្តផង។ ករណីដែលទើបនឹងលើកមកនេះសំខាន់ណាស់ ព្រោះបង្ហាញថាមិនមែនជាការលេងសើចឡើយ ដែលគេអនុញ្ញាតឲ្យកូនស្រីទទួលប្រុសកម្លោះនៅពេលយប់ដូច្នោះ។

ដូចបានពោលពីលើមកហើយ ជាធម្មតាអ្នកទាំងពីរតែងរៀបការគ្នាជាប្តីប្រពន្ធនៅទីបញ្ចប់។ ដើម្បីទៅដល់ដំណាក់កាលនោះ ខាងប្រុសត្រូវទៅរកមនុស្សគូគ្នាជាប្តីប្រពន្ធឲ្យទៅចរចានិងឪពុកម្តាយខាងស្រី។ បើក្មេងស្រីនិងប្រុស

[៩] ឧទាហរណ៍នៅភូមិកាន់ជឹង និងភូមិក្រេះ។

[១០] ឧទាហរណ៍នៅភូមិកាឡា។

[១១] ផាកនោះ ពីមុនមកគឺអ្នកដែលមានកំហុសត្រូវចេញស្រា និងសត្វ មានជ្រូកនិងមាន់ជាដើមសម្រាប់យកមកសែន ដើម្បីឲ្យអ្នកភូមិទាំងអស់បានរួចខ្លួនចៀសផុតពី “មន្ទិល” ដែលខ្លួនបានបង្ករមក។ សព្វថ្ងៃនេះ អ្នកមានកំហុសអាចចេញជាប្រាក់កាសក៏បាន ដើម្បីឲ្យគេទៅទិញវត្ថុទាំងនោះមកសែនដូចគ្នាដែរ។

[១២] នេះជារយៈពេលមធ្យម ដែលក្មេងក្រមុំគ្រឹងស្នាក់នៅក្នុងកូនផ្ទះផ្ទាល់ខ្លួនដាច់ពីឪពុកម្តាយ។

នោះនៅភូមិខុសគ្នា គេតែងតែរៀបការនៅភូមិខាងស្រីដោយឳពុកម្ដាយកូនស្រីនោះជាអ្នកចាត់ចែង។ បើចង់រៀបការនៅភូមិខាងប្រុសផង គឺត្រូវធ្វើក្រោយអំពីនោះ។

យើងបាននិយាយមកហើយថាចំពោះទំនៀមពាក់ព័ន្ធនឹងក្មេងស្រីក្រមុំ គ្រឹងហាក់ដូចជានៅប្រកាន់ទំនៀមទម្លាប់ដើមច្រើនជាងជាតិពន្ធុដែលនៅជិតខាងខ្លួន។ តាមពិតទៅ ពីមុននេះបន្តិច ជនជាតិខ្លះទៀត ជាពិសេសពួកព្រៅក៏មានទំនៀមដូចគ្នានេះដែរ។ គេអាចសួរថា បើត្រូវការដកឃ្លាថយក្រោយមកមើលជាតិសាសន៍ជាបងប្អូន ដើម្បីស្វែងយល់ប្រពៃណីខ្លួនឯងនោះ ហេតុម្ដេចបានជាទាល់តែជ្រើសរើសជាតិពន្ធុដែលនៅភូមិភាគឦសាន? ចម្លើយគឺថា បើយើងយកជាតិសាសន៍អម្បូរមន_ខ្មែរដូចជាគួយ, ព័រ, ស្អូច ជាដើមនោះមកពិចារណាឃើញថាការថយក្រោយឬដកឃ្លារកយល់ខ្លួនឯងនោះពុំអាចវែងឆ្ងាយទេ ព្រោះអ្នកអម្បាលម៉ានខាងក្រោយនេះនៅជិតខ្មែរ ឆ្លងអារ្យធម៌តាមខ្មែរជាច្រើនសតវត្សណាស់មកហើយ បើនិយាយពីជនជាតិសម្រែនៅតំបន់អង្គរផង ស្ទើរតែអាចថាដាច់ពូជថ្មីៗនេះទៅហើយក៏ថាបានដោយសារលាយចូលគ្នាជាមួយខ្មែរ ហើយក្លាយទៅជាខ្មែរអស់។ ឈ្មោះថ្ងៃឈ្មោះខែជាដើមសុទ្ធសឹងជាពាក្យសំស្ក្រិតដោយសារខ្ចីបន្តអំពីខ្មែរទៅ មានន័យថាការរាប់នឹងគិតគូរពីពេលវេលាក៏ឆ្លងតាមខ្មែរ។ រីឯខ្មែរវិញ ក៏ទទួលឥទ្ធិពលនេះជាយូរយាមកហើយពីឥណ្ឌា។ រឿងនេះគេដឹងច្បាស់អស់ហើយ ពុំចាំបាច់លើកមកនិយាយទៀតទេ។ ប្រការដែលចង់បញ្ជាក់គឺថាបើចង់ធ្វើការប៉ាន់ស្មានខ្លះថា កាលពីមុនជ្រួតជ្រាបអារ្យធម៌ធំៗ ដូចជាអារ្យធម៌ឥណ្ឌាជាដើមនោះ តើប្រពៃណីខ្មែរប្រហែលជាមានលំនាំរបៀបណា ទាល់តែងាកទៅរកមើលជាតិពន្ធុជាបងប្អូនដែលរស់នៅទឹកដីម្ដុំៗគ្នានេះ តែដែលបែកចេញពីខ្មែរជាយូរមកហើយ ឥតមានទទួលអារ្យធម៌ធំៗដូចខ្មែរ ឬតាមរយៈខ្មែរ។ ពោលមកនេះ ពុំមានន័យថាកាលពីមុនសម័យប្រវត្តិសាស្ត្រខ្មែរដូចគ្រឹង, ដូចព្រៅ, ដូចទំពួន...ជាទូទៅនោះដែរ គឺគ្រាន់តែជាការប៉ាន់ស្មានប្រមើលងាកមកក្រោយថា មុននឹងដើរមកដល់ប្រពៃណីចូលម្លប់ ហើយបន្ទាប់មកទើបរៀបមង្គលការនោះ កាលពីព្រេងនាយប្រហែលជាខ្មែរមានទំនៀមដូចម្ដេចដែរ។

## ប្រៀបធៀបខ្មែរ នឹងគ្រឹង

តើដំណើរពីភាពក្រមុំទៅដល់ភាពជាភរិយាផ្ទុយគ្នាណាស់ទៅឬ រវាងខ្មែរនឹងគ្រឹង? បើមើលតែមួយភ្លែតហាក់ដូចជាឃ្លាងឃ្លាតឆ្ងាយពីគ្នាណាស់ មួយបង្ខាំងខ្លួនជិតក្នុងបន្ទប់មិនឲ្យនរណាឃើញ មួយទៀតទទួលប្រុសឲ្យនៅជាមួយដោយគ្មានលាក់លៀម។ បើពិចារណាវែងឆ្ងាយទើបឃើញថា ទំនៀមដែលខុសគ្នាខ្លាំងនៅត្រង់ចំណុចថា ក្រមុំគ្រឹងឬជាតិពន្ធុដែលនៅជិតនោះត្រូវរើសគូស្រករខ្លួនឯង ខុសឬត្រូវនៅលើខ្លួនផ្ទាល់។ គេសង់កូនផ្ទះឲ្យនោះ ក៏សម្រាប់បំពេញសេរីភាពនោះឯងហើយ។ រីឯក្រមុំខ្មែរវិញ ដើម្បីមានគូស្រករទាល់តែ “ម្ដាយទុកឳពុកដាក់” (យ៉ាងហោចណាស់ក៏ជាទ្រឹស្ដីដែរ)។ ក្រៅពីចំណុចនេះ ពុំឃើញមានអ្វីដែលអាចពោលថាផ្ទុយគ្នាបានទេ។ ពុំត្រឹមតែមិនផ្ទុយ គឺថែមទាំងអ្វីៗផ្អែក

ទៅលើគោលគំនិតដូចគ្នាទៀតផង។

គំនិតទីមួយបាននិយាយមកខាងលើហើយ ចំពោះខ្មែរ គឺថាពីចាប់ផ្ដើមក្រមុំមកដល់ក្លាយជាប្រពន្ធ ស្រីខ្មែរឆ្លងដំណាក់កាលតូចៗច្រើនណាស់ តែអាចសង្ខេបមកបានថាឆ្លងដំណាក់កាលធំៗពីរ។ ដំបូងត្រូវឆ្លងកាត់ "ម្លប់" ដែលធ្វើវិភាគទៅឃើញថាជាការឧបកិច្ចថាមានប្ដី។ បន្ទាប់មកទើបឆ្លងដំណាក់កាលដែលហៅថាមង្គលការ ពោលគឺដំណាក់កាលចុងក្រោយធ្វើឲ្យសង្គមទទួលស្គាល់ថានាងនោះជាភរិយាគេ។ រីឯគ្រឹះវិញក៏ឆ្លងដំណាក់កាលតូចៗច្រើនដូចគ្នា ហើយសង្ខេបមកបានជាពីរដូចគ្នា គ្រាន់តែដំណាក់កាលធំទីមួយពុំមែនជាការឧបកិច្ច ឬក៏ធ្វើអ្វីៗឡើងជានិមិត្តរូបទេ តែគឺជាជំហានទីមួយទៅរកការមានប្ដីពិត ព្រោះនាងនោះរួមរស់ខ្លួនប្រាណជាមួយសង្សារពិតប្រាកដ។ ដើម្បីឲ្យសង្គមទទួលស្គាល់ភាពជាភរិយានោះ លុះត្រាតែឆ្លងមួយដំណាក់ទៀត គឺរៀបការដូចខ្មែរដែរ។

មូលដ្ឋានគំនិតនៃដំណាក់កាលធំទីមួយនោះមានដូចគ្នា ពោលគឺផ្អែកលើនិមិត្តរូបនៃការចូលទៅនៅក្នុងផ្ទៃម្ដាយមួយរយៈសិន ទើបកើតចេញមកវិញក្នុងស្ថានភាពជាស្រីដែលអាចមានប្ដីពេញមុខបាន។ ចំពោះខ្មែរនិមិត្តរូបនេះមើលឃើញច្បាស់ណាស់។ បន្ទប់ដែលជាម្លប់នោះគឺជាឧទររបស់ម្ដាយ។ ពេលចេញពីម្លប់វិញ ទម្រាំចេញផុតស្រឡះមកសំពះព្រះអាទិត្យ ត្រូវឆ្លងកាត់ស្ថានភាពផ្សេងៗពីរបីគន្លាក់។ ឧទាហរណ៍ចេញផុតពីបន្ទប់ហើយត្រូវទៅចូលក្នុងមុងឬក្នុងបុស្បុកមួយសាទៀតសិន, ឯការដែលដើរទៅនោះក៏គេយកសំពត់សបាំង ប្រដូចទៅនឹងទារកដែលពុំទាន់ផ្ដាច់ខ្លួនជ្រះស្រឡះពីទងផ្ចិតនិងសុកជាដើម។ មិនត្រឹមតែប៉ុណ្ណោះ គេប្រដូចរបៃគុបតែងមុខក្មេងស្រីនោះទៅនឹងទឹកភ្លោះទៀតផង[១៣]។ បើមើលមកគ្រឹះពុំឃើញថាស្ដែងដល់នោះទេ តែយ៉ាងណាក៏សូមកុំភ្លេចថាកូនផ្ទះនោះគេធ្វើឲ្យមានភាពចង្អៀតណាស់ ម្យ៉ាងទៀតពេលឈប់នៅ (ពោលគឺពេលសម្រេចថាឲ្យរៀបការជាមួយកម្លោះដែលក្មេងស្រីនោះរួមរស់គ្នាបានហើយ) គេត្រូវរុះចោលឬមួយបង្វែរទិសហើយប្ដូរទីកន្លែង មានន័យថាកូនផ្ទះនោះគ្រាន់តែជាស្ថានភាពបណ្ដោះអាសន្នមួយដូចជាពោះពង់ស្រីដែលមានគភ៌ដូច្នោះដែរ។

ក្នុងសម័យប្រវត្តិសាស្ត្រ ជាតិសាសន៍មានខ្មែរជាដើមនេះ ដែលទទួលឥទ្ធិពលអារ្យធម៌ធំៗនៅបុរាណកាល ជាពិសេសអារ្យធម៌ឥណ្ឌា មានការវិវឌ្ឍន៍វែងឆ្ងាយខ្លាំងណាស់ ដូចយើងដឹងស្រាប់។ រីឯជាតិពន្ធុនៅភូមិភាគឦសានដែលបានលើកឡើងមានគ្រឹងជាដើមនេះ ថ្វីត្បិតតែពុំនៅទ្រឹង[១៤] ក៏ការវិវឌ្ឍន៍សង្គមពុំមានល្បឿនអ្វីខ្លាំងក្លាទេ មកទល់ពេលថ្មីៗនេះ[១៥]។ ទោះជាយ៉ាងនេះក្ដី ក៏យើងទើបនឹងបានឃើញមកហើយថា បើកោសយកសម្បកក្រៅចេញ ខ្លឹមនៅខាងក្នុងពុំងាយប្រែប្រួលទៅណាឡើយ។ ក្រមុំខ្មែរដែលចូលម្លប់ ពុំខុសគ្នាអ្វីខ្លាំងពីក្រមុំគ្រឹងដែលស្នាក់នៅកូនផ្ទះតូចមួយរយៈពេលនោះទេ។

---

[១៣] ដើម្បីពិស្ដារសូមអានសៀវភៅដែលបាននិយាយខាងលើរួចហើយ ៖ អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប ២០០៧។

[១៤] លើលោកនេះពុំដែលមានសង្គមមនុស្សណានៅទ្រឹងទេ គឺតែងមានការវិវឌ្ឍន៍ជានិច្ច គ្រាន់តែល្បឿននៃការវិវឌ្ឍន៍នោះខុសៗគ្នា លឿនឬយឺតទៅតាមទេសកាលខុសៗគ្នានៃប្រវត្តិសាស្ត្រ។

[១៥] តែអំណើះតទៅមុខ ស្ថានការនេះនឹងដូរចាប់រហ័ស ដោយសារជាតិពន្ធុទាំងនេះប្រាស្រ័យទាក់ទងជាមួយខ្មែរកាន់តែខ្លាំងទៅៗ។

***Résumé***

*« Vers l'état d'épouse », par Sun Chandeb et Hing Chanthant*

*L'impressionnant et coûteux rite de passage, en général tombé en désuétude, appelé « Retraite dans l'ombre » est encore sporadiquement observé. Il sanctionne la nubilité de la jeune fille khmère et la rend apte au mariage. A toutes les phases du rite, la postulante est implicitement montrée avec un époux factice. Considérée isolément dans son propre contexte cambodgien, le rite est, bien sûr, rendu parfaitement intelligible par l'analyse. Reste cependant son côté insolite, bizarre même : à quoi correspond ce besoin de simulation avant qu'une union matrimoniale réelle n'ait lieu plus tard ? Un peu de recul, dès lors, apparaît nécessaire. L'examen minutieux des pratiques chez les Kreung, population môn-khmère habitant la province de Ratanakiri, relatives au laps de temps qui va de l'apparition des premières règles de la jeune fille à son mariage officielle, nous donne un éclairage déterminant. La jeune fille Kreung ne se contente pas d'une union factice avant la reconnaissance officielle, l'union avec le fiancé de son propre choix se produit réellement et, sauf accident, débouche sur le mariage. Factice ou réelle donc, l'union n'en est pas moins symboliquement un pré-mariage.*

***Abstract***

*"Approaching Wifehood", by Sun Chandeb et Hing Chanthant*

*The impressive and costly rite of passage called "Retreat into the Shade," is only sporadically practiced today. The rite sanctions a young girl's nubility, and renders her apt for marriage. At each phase of the rite, the postulant is implicitly placed before an artificial husband. Examined in an isolated manner within the Cambodian context, the rite is perfectly intelligible. There remains nonetheless a surprising, even bizarre dimension: how do we understand the need for simulation prior to the actual matrimonial union? Some distance allows for analysis of the issue. Close study of practices amongst the Kreung, a Mon-Khmer population in Ratanakiri province, relative to the lapse of time between the girl's first menstrual period and her official marriage, provides a key to understanding here. The young Kreung girl is not satisfied with a simulated union prior to official marriage; union with the fiancé of her choosing is actually held and, generally, leads to marriage. Simulated or real, therefore, the union is always a symbolic pre-marriage.*

## ឯកសារពិគ្រោះ

ជ័យ រតនា និង ឡុង ពៅ, ២០០១_២០០២, សហគមគ្រឹង ខេត្តរតនគិរី, ជំហានដំបូងនៃការសិក្សាអំពីប្រព័ន្ធគ្រួសារ និងសង្គមរស់នៅ, សារណាសម្រាប់យកបរិញ្ញាបត្របុរាណវិទ្យា, មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ស៊ុន ចាន់ដឹប, ២០០៣, ពិធីចូលម្ឌប់, សារណាសម្រាប់យកបរិញ្ញាបត្របុរាណវិទ្យា, មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ស៊ុន ចាន់ដឹប, ២០០៦, ការបែកវិស័យមនុស្សប្រុសនិងស្រី នៅពេលពេញវ័យ, សារណាសម្រាប់យកបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកបុរាណវិទ្យា, រាជបណ្ឌិតសភាកម្ពុជា_សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ហ៊ីង ច័ន្ទថន, ២០០៧, ស្ត្រីជនជាតិគ្រឹង, សារណាសម្រាប់យកបរិញ្ញាបត្របុរាណវិទ្យា, មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, ២០០៧, ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ, ហនុមានទេសចរណ៍, ភ្នំពេញ។

Matras-Troubetzkoy, Jacqueline, 1983, *Un village en forêt. L'essartage chez les Brou du Cambodge*, SELAF, Paris.